ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ០៥៦ ស.អ.យ.

ភ្នំពេញ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០

# ប្រកាស
## ស្តីពី
## ការបង្កើតរដ្ឋបាលសិទ្ធិជនពិការ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
-បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០០៥ ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅមជ្ឈមណ្ឌលរដ្ឋ
-បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត **រដ្ឋបាលសិទ្ធិជនពិការ** សរសេរជាអក្សរកាត់ថា "**រ.ស.ជ.**" ជាភាសាអង់គ្លេស Disability Rights Administration "D.R.A" ជាអង្គភាពចំណុះនាយកដ្ឋានស្តារលទ្ធភាពពលកម្ម នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ប្រការ ២.-**

រដ្ឋបាលសិទ្ធិជនពិការ មានតួនាទី និងភារកិច្ចដូចខាងក្រោម :



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៤
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 084

- ផ្សព្វផ្សាយគោលនយោបាយ ផែនការជាតិ ច្បាប់ជាតិ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ
- ត្រួតពិនិត្យ តាមដាន និងជម្រុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
- សម្របសម្រួលក្នុងការលើកទឹកចិត្តដល់ជនពិការ ក្រសួង ស្ថាប័ន និយោជក និងគ្រឹះស្ថានខាងៗ ឱ្យអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនពិការ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជន ព្រមទាំងអង្គការពាក់ព័ន្ធខាងៗ
- ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ដោះស្រាយទំនាស់ផ្សេងៗ ដែលកើតឡើងក្នុងក្របខណ្ឌនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ទាត់វិធានការពិន័យអន្តរការណ៍តាមមាត្រា ៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចំពោះក្រសួង ស្ថាប័នរដ្ឋ គ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន ដែលខកខានមិនបានបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- កសាងសំណុំរឿងប្តឹងទៅតុលាការ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមកាលកំណត់ ។

**ប្រការ ៣.-**

និតិវិធីនៃការធ្វើអធិការកិច្ច និងវិធានការព្រមាន ដាក់កំហិត និងដាក់ពិន័យត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ ៤.-**

រដ្ឋបាលសិទ្ធិជនពិការ ដឹកនាំដោយប្រធានមួយរូបដែលជាអនុប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម និងមានអនុប្រធានមួយចំនួន ជាជំនួយការ មានឋានៈស្មើប្រធានការិយាល័យថ្នាក់ក្រសួង ។

**ប្រការ ៥.-**

រដ្ឋបាលសិទ្ធិជនពិការ មានរចនាសម្ព័ន្ធ ដូចខាងក្រោម :

១- ផ្នែករដ្ឋបាល

២- ផ្នែកពិគ្រោះយោបល់ សម្របសម្រួល និងផ្សព្វផ្សាយ

៣- ផ្នែកអធិការកិច្ច

**១- ផ្នែករដ្ឋបាល មានភារកិច្ច :**

- គ្រប់គ្រងលិខិតចេញ-ចូល និងបណ្ណសារ
- គ្រប់គ្រងបុគ្គលិក

- គ្រប់គ្រងស្ថិតិជនពិការដែលត្រូវទទួលបានសេវាផ្សេងៗតាមច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- គ្រប់គ្រងបញ្ជីសារពើភ័ណ្ឌ សម្ភារៈ និងគ្រឿងបរិក្ខារ
- ផ្សព្វផ្សាយបទបញ្ញា សារាចរ សេចក្តីសម្រេច សេចក្តីជូនដំណឹងផ្សេងៗ របស់ថ្នាក់លើ
- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំរបស់រដ្ឋបាលសិទ្ធិជនពិការជូនប្រធានរដ្ឋបាលសិទ្ធិជនពិការ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសិទ្ធិជនពិការប្រគល់ជូន ។

## ២- ផ្នែកពិគ្រោះយោបល់ សម្របសម្រួល និងផ្សព្វផ្សាយ

- ផ្សព្វផ្សាយគោលនយោបាយ ផែនការជាតិ ច្បាប់ជាតិ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ
- ផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ដល់ជនពិការ ក្រសួង ស្ថាប័ន គ្រឹះស្ថានសាធារណៈ ផ្នែកឯកជន ព្រមទាំងអង្គការពាក់ព័ន្ធនានា
- ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតឡើងក្នុងក្របខណ្ឌនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- សហការទំនាក់ទំនង និងសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និយោជក និងគ្រឹះស្ថាននានា ដើម្បីលើកកម្ពស់កិច្ចសហការ និងកិច្ចសហប្រតិបត្តិការ ក្នុងការជួយជនពិការ លើការងារ :

    -ជីវភាពរស់នៅ

    -ការស្តារកាយសម្បទា និងសតិបញ្ញា ការថែទាំសុខភាព និងការបង្ការ

    -ការចេញចូលទីកន្លែងសាធារណៈ

    -ការអប់រំ

    -ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

    -ការលើកទឹកចិត្ត

    -ការបោះឆ្នោត

    -ការទទួលផលប្រយោជន៍ពីមូលនិធិជនពិការ

- សហការជាមួយក្រសួងព័ត៌មាន និងស្ថាប័នពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយអំពីបញ្ហាពិការភាព និងសិទ្ធិជនពិការឱ្យបានទូលំទូលាយ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន
- សហការជាមួយមូលនិធិជនពិការដើម្បីប្រមូលភាគទាន និងអំណោយសប្បុរសធម៌ផ្សេងៗ បញ្ចូលក្នុងមូលនិធិជនពិការ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលប្រធានរដ្ឋបាលសិទ្ធិជនពិការប្រគល់ជូន ។

## ៣- ផ្នែកអធិការកិច្ច

- ត្រួតពិនិត្យ តាមដាន និងជំរុញការអនុវត្តច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- សម្របសម្រួលក្នុងការលើកទឹកចិត្តដល់ជនពិការ ក្រសួង ស្ថាប័ន និយោជក និងគ្រឹះស្ថាននានា ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ផ្តល់សេវាសម្របសម្រួល ផ្សះផ្សា ជួយដោះស្រាយនូវវិវាទផ្សេងៗ ដែលកើតឡើងក្នុងក្របខណ្ឌនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

- ធ្វើអធិការកិច្ចចំពោះក្រសួង ស្ថាប័នរដ្ឋ និងនីតិបុគ្គល ស្របតាមច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- ចាត់វិធានការពិន័យអន្តរការណ៍តាមមាត្រា ៥៤ នៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចំពោះក្រសួង ស្ថាប័នរដ្ឋ គ្រឹះស្ថានសាធារណៈ គ្រឹះស្ថានឯកជន ដែលខកខានមិនបានបំពេញកាតព្វកិច្ចដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- កសាងសំណុំរឿងប្តឹងទៅតុលាការ ចំពោះអ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ
- អនុវត្តការកិច្ចផ្សេងៗទៀតដែលប្រធានរដ្ឋបាលសិទ្ធិជនពិការប្រគល់ជូន ។

**ប្រការ ៦.-**

បង្កើតសាខារដ្ឋបាលសិទ្ធិជនពិការ នៅតាមមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ។ សាខារដ្ឋបាលសិទ្ធិជនពិការស្ថិតនៅក្រោមការិយាល័យសុខុមាលភាពសង្គម នៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ។

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវលើកសំណើកំណត់ចំនួន និងសមាសភាពនៃសាខារដ្ឋបាលសិទ្ធិជនពិការនៅរាជធានី ខេត្ត របស់ខ្លួនមករដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចតាមរយៈនាយកដ្ឋានស្តារលទ្ធភាពពលកម្ម ។

**ប្រការ ៧.-**

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលសិទ្ធិជនពិការត្រូវមានលក្ខណៈសម្បត្តិ :

-មានបទពិសោធន៍ការងារសង្គមកិច្ច ជាពិសេសការងារពិការភាព
-បានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច តាមកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
-មានបទពិសោធន៍ផ្នែកច្បាប់
-មានសមត្ថភាពភាសាអង់គ្លេស និងកុំព្យូទ័រ ។

ជាមន្ត្រីក្របខណ្ឌរដ្ឋរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមកពីក្រសួង ស្ថាប័នផ្សេងៗ ។

**ប្រការ ៨.-**

អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានស្តារលទ្ធភាពពលកម្ម ត្រូវរៀបចំសំណើបង្កើតរដ្ឋបាលសិទ្ធិជនពិការនៅសាខារាជធានី ខេត្ត និងរៀបចំការបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលសិទ្ធិជនពិការគ្រប់ថ្នាក់ ឱ្យមានសមត្ថភាពបំពេញបេសកកម្មរបស់ខ្លួន ។

**ប្រការ ៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ១០.-

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង និងប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។៚

ស៊ុក សំអេង

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម និងលោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួង ស.អ.វ
- ក្រុមប្រឹក្សាសកម្មភាពជនពិការ
- មូលនិធិជនពិការ
- ដូចប្រការ ១០
- ឯកសារ-កាលប្បវត្តិ